ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ១១៦/១៧ គ.ជ.ប.ជ

# កំណត់ហេតុកិច្ចប្រជុំ
## ឆ្លងផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តបន្តឆ្នាំ ២០១៧-២០១៨ ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែកក្កដា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំអន្តរក្រសួង ឆ្លងផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តបន្តឆ្នាំ ២០១៧-២០១៨ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍**គ.ជ.ប.ជ ។

សមាសភាពចូលរួមសរុបចំនួន **៨៧នាក់ (ស្រី ៤៩នាក់)** រួមមានតំណាងមកពី ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងទេសចរណ៍ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងធម្មការនិងសាសនា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អភិបាល-អភិបាលរងនិងស្នងការរង២៥រាជធានី-ខេត្ត និងអង្គការ CCPCR, WI, Chab Dai, UN-ACT, IOM, Cambodia ACTs, Samaritan's Purse, IJM ។

គោលបំណងនៃកិច្ចប្រជុំគឺ តាមដានត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកន្លងមក និងពិនិត្យកែសម្រួលផែនការសកម្មភាពសម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ ។

**ជាកិច្ចចាប់ផ្តើម លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍ណែនាំអំពីកិច្ចការដែលនឹងត្រូវធ្វើក្នុងការពិនិត្យកែសម្រួលផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានដូចខាងក្រោម៖**

- តាមរយៈការតាមដានត្រួតពិនិត្យការអនុវត្តកន្លងមក យើងសង្កេតឃើញថាសកម្មភាពដែលបានអនុវត្តគឺមិនស្របតាមផែនការដែលបានដាក់ទាំងអស់នោះទេ គឺវាបានប្រែប្រួលទៅតាមស្ថានការណ៍ដែលទើបកើតមានឡើងថ្មីៗ ដូចនេះយើងត្រូវធ្វើការពិនិត្យកែសម្រួលនូវផែនការដែលយើងបានដាក់ ថាសកម្មភាពណាដែលបានអនុវត្តរួចហើយ សកម្មភាពណាមិនទាន់បានអនុវត្ត តើត្រូវទុក ត្រូវដកចេញ ឬត្រូវដាក់បន្ថែមអ្វីថ្មីទៀត និងត្រូវមើលអំពីសូចនាករផងថាអាចអនុវត្តបានឬមិនអាច បើមិនអាចកុំដាក់ចូល ។ អ្វីដែលសំខាន់នោះគឺ ត្រូវលើកយកសកម្មភាពណាដែលជាអាទិភាពរបស់ក្រសួង-ស្ថាប័នខ្លួន ដើម្បីដាក់បញ្ចូល ហើយសកម្មភាពទាំងនោះត្រូវស្របតាមយុទ្ធសាស្ត្រទាំងបួនដែលមានស្រាប់ ។

- ចង់ដឹងថាតើមានខេត្តណាខ្លះ ឬក្រសួងណាខ្លះបានយកផែនការសកម្មភាពរួមទៅបំបែកបន្ត ឬមានផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួនសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- ការវាយតម្លៃចំណាត់ថ្នាក់របស់អាមេរិក បានឲ្យកម្ពុជានៅលេខ២ដដែល ដោយសាររបាយការណ៍មិនបានរំលេចសកម្មភាពច្រើន តែគេបានដឹងថាយើងបានខិតខំប្រឹងប្រែងធ្វើការយ៉ាងសកម្ម ។ ទិន្នន័យ និងរបាយការណ៍កន្លងមក ភាគច្រើនគឺយកពីសារព័ត៌មានផ្សេងៗ ចំណែកតាមក្រសួង-ស្ថាប័ន និងរាជធានី-ខេត្តនៅមានភាពខ្វះចន្លោះច្រើន ដែលត្រូវការការកែលម្អ និងពង្រឹងបន្ថែម ។

បន្ទាប់មក តំណាងអង្គការ Winrock បានធ្វើបទបង្ហាញអំពីលទ្ធផលវាយតម្លៃផែនការសកម្មភាពជាតិពាក់កណ្តាលអាណត្តិ ២០១៤-២០១៨ ។ ក្រុមការងារសម្របសម្រួលកិច្ចប្រជុំ បានចែកក្រដាសជូនសមាជិកអង្គប្រជុំទាំងអស់ ដើម្បីបំពេញបន្ថែមនូវផែនការសកម្មភាពរបស់ខ្លួន ដែលមិនទាន់បានដាក់បញ្ចូល ឬត្រូវកាត់ចោល ឬត្រូវកែសម្រួល ហើយក្រដាសលទ្ធផលនេះត្រូវបានប្រមូលនៅចុងកិច្ចប្រជុំ ដើម្បីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ យកទៅបញ្ចូលក្នុងផែនការសកម្មភាពជាតិ ។

**កិច្ចប្រជុំបានប្រព្រឹត្តទៅដោយមានចូលរួមមតិយោបល់ពីសមាជិក ដូចខាងក្រោម៖**

- **<u>ប្រសាសន៍ លោកជំទាវ យូ សុភា អភិបាលរងខេត្តសៀមរាប ៖</u>**
  - ពលករខ្ចីលុយគេដើម្បីរត់ការចេញទៅ ពេលចាញ់បោកមេខ្យល់ ពលកររេះតែមករករឿងនគរបាលប្រឆាំងការជួញដូរមនុស្ស ដើម្បីទារសំណង ។ ហើយពេលចាប់មេខ្យល់បាន តុលាការកាត់ទោសចេញសាលក្រមឲ្យសងសំណង តែមិនបានសង ។
  - បញ្ហាក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយកន្លែងខ្លះកំណត់កម្រិតវប្បធម៌ តែពលករមួយចំនួនដែលត្រឡប់មកវិញគឺមិនបានរៀនសូត្រទេ ។
- **<u>ប្រសាសន៍ លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ ៖</u>**
  - សមាជិកក្រុមការងារអនុវត្តច្បាប់បានទំនាក់ទំនងគ្នាតាមរយៈតេឡេក្រាមជាប្រចាំ ដោយសារការកោះប្រជុំមានការលំបាក ។ ផែនការសកម្មភាពរបស់ក្រុមបានធ្វើ និងកែសម្រួលរួចហើយត្រឹមឆ្នាំ២០១៧ និងត្រូវការពេលបន្តិចទៀតដើម្បីធ្វើឆ្នាំ២០១៨ ។

**ជាទីបញ្ចប់ លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍សរុបមតិ និងណែនាំការងារមួយចំនួនដូចខាងក្រោម៖**

- កញ្ចប់ថវិកាទើបតែមាន២ឆ្នាំចុងក្រោយនេះទេ ។
- ការស្នើកញ្ចប់ថវិកាទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ទៅ បើគេកាត់គេជូនដំណឹងហើយ ។
- យើងសង្កេតឃើញថាសកម្មភាពយើងធ្វើដដែលៗ តែអ្វីដែលសំខាន់នោះគឺផ្តោតលើជនជាមនុស្សដែលកំពុងតែរងគ្រោះ ។
- យើងមានអនុស្សរណៈយោគយល់ជាមួយថៃ ដែលនាំឲ្យរង់ចាំថៃបញ្ជាក់តម្រូវការដែលតិចជាងចំនួនពលករត្រូវការការងាររាប់សិបដង ដូចនេះបានជាពលករចេញទៅដោយមិនចាំយើង ។
- បុគ្គលិករបស់យើងមានច្រើន តែធ្វើការមិនចំទិសដៅ និងមិនមានអ្នកទទួលខុសត្រូវច្បាស់លាស់ ។
- សូមបន្តស្វែងរកសកម្មភាពដែលជាគន្លឹះសំខាន់ និងជាអាទិភាព មើលថាត្រូវថែម ឬកាត់ចោល ឬត្រូវទុកដដែល និងដាក់សូចនាករឲ្យបានច្បាស់លាស់ ។ ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន អង្គភាពណាក៏ដោយឲ្យតែពាក់ព័ន្ធនឹងការងារជួញដូរមនុស្ស សូមជូនដំណឹងឲ្យ គ.ជ.ប.ជ បានដឹងផង ។

- ត្រូវតាមដានការអនុវត្ត និងលទ្ធផល បានលទ្ធផលអីដាក់ចូលមក កន្លងមកបានធ្វើតែមិនឃើញរំលេចលទ្ធផល ។
- ក្រុមការងារអន្តរក្រសួងមិនទាន់បានជួបប្រជុំគ្នា ដែលនាំឲ្យខ្វះកិច្ចសហការ មិនបានដឹងអំពីវិធានការថ្មីៗ និងធ្វើការងារមិនមានការឯកភាពគ្នា ដូចនេះក្រុមការងារនីមួយៗត្រូវចាប់ផ្តើមកោះប្រជុំសមាជិករបស់ខ្លួន ។
- ពេលត្រឡប់ទៅវិញ សូមយកផែនការទៅពិភាក្សាជាមួយសមាជិករបស់ខ្លួន ដើម្បីឲ្យមានការឯកភាពគ្នា យើងត្រូវការឲ្យមានការឯកភាពគ្នា ស៊ីសង្វាក់គ្នាក្នុងគោលដៅរួមតែមួយ ។
- បើខាងណាមិនចេះរៀបចំផែនការ ជូនដំណឹងមក យើងនឹងរកគ្រូបង្រៀន ។
- សូមខិតខំ និងយកចិត្តទុកដាក់ក្នុងការងារជាងមុន ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរ និងសាមសិបនាទីថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី០៧ខែសីហាឆ្នាំ២០១៧
**អ្នកធ្វើកំណត់ហេតុ**

ទ.ត្រី ប៉ា.រតនៈ

គោរពជូន លោកជំទាវ
អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជាដំណឹងខ្ពង់ខ្ពស់ ។
ភ្នំពេញ ថ្ងៃទី០៧ខែសីហា ឆ្នាំ២០១៧
**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ទោ. **គង់_ពុទ្ធី**

បានឃើញ
ជ.ឯ គណៈ
08/08/17

**ជូ_ប៊ុនអេង**